# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ

## សារថ្វាយព្រះពរ

## សូមក្រាបបង្គំទូលថ្វាយ

## សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ

## ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់

ក្នុងឱកាសរំលឹកខួបអនុស្សាវរីយ៍លើកទី១០៦ ទិវាអន្តរជាតិនារី ៨មីនា ទូលព្រះបង្គំជាខ្ញុំ ភរិយា ព្រមទាំងបុត្រ និងតាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ព្រមទាំងនាយទាហាន នាយទាហានរង ពលទាហាន ទាំងអស់នៃកងយោធពលខេមរភូមិន្ទ សូមព្រះបរមរាជានុញ្ញាតបួងសួងដល់វត្ថុស័ក្តិសិទ្ធិក្នុងលោក សូមថ្វាយសព្ទសាធុការពរបវរសួស្តីសិរីមង្គលមហាប្រសើរចំពោះ **សម្តេចព្រះមហាក្សត្រីសម្តេចម៉ែ** សូមព្រះអង្គមានព្រះរាជកាយពលមាំមួន ព្រះបញ្ញាញាណឈ្លាសវៃ ព្រះជន្មាយុយឺនយូរ ដើម្បីគង់ជាម្លប់ដ៏ត្រជាក់ដល់ប្រជារាស្ត្រជាកូនចៅ ចៅទួតរបស់ព្រះអង្គជាដរាបរៀងទៅ។

ទូលព្រះបង្គំយើងខ្ញុំជាកូនចៅព្រះអង្គ សូមព្រះរាជានុញ្ញាតក្រាបបង្គំទូលថ្វាយ នូវកតញ្ញូតាធម៌ដ៏ខ្ពង់ខ្ពស់បំផុត ចំពោះព្រះមហាករុណាទិគុណដ៏ធំធេង ដែល **សម្តេចព្រះមហាក្សត្រីសម្តេចម៉ែ** បានប្រោសប្រទានដល់ប្រជារាស្ត្រជាកូនចៅព្រះអង្គ តាមរយៈព្រះរាជបេសកកម្មជាប្រវត្តិសាស្ត្រ ចូលរួមជាមួយ **ព្រះករុណាព្រះបរមរតនកោដ្ឋ** ការពារយ៉ាងរឹងមាំនូវឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដី ក្នុងកាលកន្លងមក និងតាមរយៈព្រះរាជសកម្មភាពផ្ទាល់ព្រះអង្គ ផ្នែកសង្គមកិច្ច និងវប្បធម៌ដ៏ថ្លៃថ្លាបំផុត។

សូម **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល** ជាទីគោរពសក្ការៈ ទ្រង់ព្រះមេត្តាទទួលនូវគារវភក្តីភាពដ៏ខ្ពង់ខ្ពស់បំផុត អំពីទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា។

សេចក្តីគួរពុំគួរ សូមទ្រង់ព្រះមេត្តាប្រោស។

សូមក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ ថ្ងៃទី០៨ ខែមីនា ឆ្នាំ២០១៧

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**នាយឧត្តមសេនីយ៍ ទៀ បាញ់**

វិថីហ្សកឌឺម៉ីត្រូវ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ទូរស័ព្ទ-ទូរសារៈ ០២៣ ៨៨៣ ២៧៤ អ៊ីមែលៈ generalsec@mod.gov.kh